.....មនុស្សប្រុសយើងនៅរាល់ពេលដែល សម្លឹងមើលទៅស្រីណាម្នាក់ ភាពមិនងាយស្រួលក្នុងន័យប្រឆាំងគ្នារវាងគំនិតនិងអារម្មណ៍បានកើត មានឡើងមែនដែរទេ?

ដូចជាថា ម៉េចបានជាយើងស្រេកឃ្លានចង់មើលនាងបែបនេះធ្វើអី? យើងមិនគួរណាសម្លឹងមើលភេទផ្ទុយ មិនគួរលួចមើល រឹតតែមិនគួរសម្លឹងឱ្យគេដឹងខ្លួនទៅទៀត.....?

បាទ! គឺអ្វីៗប្រទាំងប្រទើសទៅដូច្នេះឯង ប៉ុន្តែចុងក្រោយ ខ្ញុំនៅតែបន្តសម្លឹងនារីម្នាក់ៗតាមវិធីរបស់ខ្ញុំ ជួនកាលគឺមានចេតនាឱ្យនាងបានដឹងដោយត្រង់ៗតែម្តង ក៏ជួនកាល ខ្ញុំក៏ពើជាមិនចាប់អារម្មណ៍មើលនាង តែត្រូវធ្វើឱ្យប្រាកដថា គ្មាននារីណាដែលនៅចំពោះមុខខ្ញុំត្រូវរំលងពីការសម្លឹងមើលរបស់ខ្ញុំនោះឡើយ។

នៅក្នុងពិភពផែនដីដែលវិលវិវត្តទៅមុខយ៉ាងលឿន និងកំពុងគ្រប់គ្រងដោយវិសាលភាពនៃថាមពលឌីជីថល គំនិតច្នៃប្រឌិតនៃបច្ចេកវិទ្យាដ៏មានតម្លៃខ្ពស់ ខ្ញុំបែរជាអស់សង្ឃឹមលើការទទួលបាននូវមនោសញ្ចេតនាស្នេហាពិត បរិសុទ្ធមួយដែលធ្លាប់តែលួងលោមយើងក្នុងបណ្តារឿងព្រេងទាំងឡាយ តាំងពីវ័យកុមាររហូតដល់ពេលដែលយើងពេញវ័យ ហើយបានប្រឡូកប្រឡាក់នឹងរឿងជាច្រើន រហូតបានក្លាយមកជាកំលោះចាស់ម្នាក់។

.....នៅក្នុងឆ្នាំនេះ គឺនៅពេលដែលតួលេខនៃអាយុខ្ញុំចាប់ផ្តើមដោយលេខ៣ ខ្ញុំកាន់តែអន្ទះសាក្នុងការស្វែងរកចម្លើយឱ្យសំណួរលាក់លៀមមួយ ចំនួនថា ដូចខ្ញុំនេះ តើរកឃើញក្តីស្រលាញ់មួយផ្អែមល្ហែមស្មោះស្ម័គ្រ ដល់ថ្នាក់ឱ្យខ្ញុំជឿជាក់លើសេចក្តីស្នេហារវាងប្រុសនិងស្រីមែន ដែរអត់? តទៅជីវិតគឺងាយស្រួល គ្មានអ្នកណាក្នុងបេះដូង ឈប់ត្រឹមនេះ ឈប់ក្នុងការស្វែងរក ឈប់ឈ្ងេងយល់ ឈប់លេងសើច និងស្នេហាលេងៗទាំងពួងដែលធ្លាប់មានមកយ៉ាងសម្បូរបែប ឬមួយត្រូវបន្តស្វះស្វែង បន្តស្មុគស្មាញជាមួយនឹងពាក្យពីរម៉ាត់នេះទៀត?

ខ្ញុំធ្លាប់សរសេរក្នុង Status ខ្ញុំបង្ហួតគេឯងថា «កោតតែពួកយើងខ្លះមានពេលសម្រាប់ទៅខូចចិត្តព្រោះស្នេហា?!»

តាម ពិត ខ្ញុំធ្វើដូចជាខ្លួនឯងនេះកំពុងមានក្តីសុខណាស់អ៊ីចឹង ប៉ុន្តែធាតុពិតទៅ ជួនកាលមិនមែនអ្វីៗដូចភ្នែកអ្នកដទៃបានឃើញឡើយ... មនុស្សមិនដែលខូចចិត្ត ក៏ពុំមែនមានន័យថា គ្រប់យ៉ាងអូខេនោះដែរ។

បើនិយាយទៅ ខ្ញុំក៏ចង់មានពេលភ្លក់ការខូចចិត្តបានម្តងនឹងគេ ក្រែងដឹងពីអ្វីទៅហៅថាលង់ស្រលាញ់

អ្នកណាម្នាក់....? តើវាឡប់ៗពេកដែរទេ សម្រាប់ប្រុសចាស់៣០ឆ្នាំដូចខ្ញុំដែលមកគិតរបៀបនេះ?... ឬមួយក៏គ្រប់គ្នាក៏បានលួចគិតអ៊ីចឹងដែរ គ្រាន់តែមិនហ៊ានទទួលស្គាល់?

....អូ....ម៉ោង៩យប់ហើយ.... ក្មេងស្រីនោះចេញមកច្រៀងទៀតហើយ... អូខេ.... យើងឈប់រវើរវាយសិន... ហើយខ្ញុំសុំពេលបីបួននាទីដើម្បីស្តាប់ចម្រៀងដែលនាងច្រៀង....

ខ្យល់បក់មកត្រសៀកៗ..... ប៉ុន្តែយប់នេះអត់មានលោកខែទេ....

នាងពិតជាចេញមកទៀងពេលមែន....។

ដៃនាងឱបត្រកងទារកតូចមួយនោះ.... ហើយសំឡេងបង្អូសស្រទោរស្រទន់របស់នាងហើរប្រាលមកដល់មាត់បង្អួចបន្ទប់ខ្ញុំ....។

ត្រឹមតែភ្នែកម្ខាងលបសម្លឹងពីទីនេះទៅ គឺពីក្រោយវាំងននសូត្រក្រាស់នេះ ខ្ញុំអាចមើលនាងឃើញទាំងស្រុងដោយមិនឱ្យនាងដឹងខ្លួនឡើយ។

ជំហានដែលនាងកំពុងឈានអែនអនរេរាំក្នុងសួន គឺមានចង្វាក់ស្រាល ល្វតល្វន់ពត់ពេន ស្មើតតខ្វោះទៅនឹកដង្ហើមចម្រៀងស្នេហ៍របស់នាងដែរ។.....

ហេតុអ្វី តាំងពីថ្ងៃទីមួយរហូតដល់យប់ទី៧នេះ ខ្ញុំហាក់ដូចជាទម្លាប់នឹងពេលវេលានេះ ទម្លាប់ក្នុងការលបលួចមើលនាងពីលើបន្ទប់ទៅ។

ហេតុអ្វីខ្ញុំដូចជាធ្លាប់ត្រចៀកជាស្រេចទៅនឹងបទចម្រៀងរបស់នាង ហើយដៃខ្ញុំអាចកូតភ្លេងតាមលំនាំបទនោះបានទាំងស្រុង មិនខ្វះមួយល្អងណា?

លំអងផ្កាចំប៉ាក្រៀមក្រោះលើដើមផ្កាចំណាស់មួយប់ត្រឈៃនៃមណ្ឌល ក្មេងកំព្រានោះ បានចុះចាញ់អនុភាពនៃសន្ទុះខ្យល់ដែលបោលបំបាក់ វាក៏ហើររុះរោយស្រោចទៅលើរាងកាយនារីតូចដែលនាងកំពុងរេរាំ។

ខ្ញុំស្តាយដែលខ្ញុំពុំមែនជាវិចិត្រករ ពុំនោះទេ ខ្ញុំនឹងគូររូបនាងទុក។

ប៉ុន្តែ .... មានអី! កាណុងកាមេរ៉ាខ្ញុំពិតជាអាចផ្តិតរូបនាងមកទុកបាន... ប្រាកដណាស់....

....ឆឹបៗៗ....

អូខេហើយ... ប៉ុន្មានថ្ងៃទៀតខ្ញុំត្រូវចាកចេញ... ហើយបើខ្ញុំពិតជានឹកនាងមែន... ហោចណាស់ ខ្ញុំមាននាងក្នុងរូបទាំងនេះ....

តោះគេង.... ការងារស្អែកជាប់គ្នារដឹកដូចសម្លកំពឹស។

មានភ្ញៀវជាច្រើនដែលត្រូវជួប កាហ្វេជាច្រើនកែវដែលត្រូវញ៉ាំ...! នេះជាគំនិតរលឹកខ្ញុំមួយ តែគំនិតមួយទៀតចេញមកប្រឆាំងវិញភ្លាម....

អូខេ... ដេត ភូមិន្ទ.... កុំទុកខ្លួនឯងជាកុំព្យូទ័រ ឬជាទាសករនៃមនុស្សទាំងនោះ ក៏មិនមែនជាទាសករនៃការលោភលន់មិនអស់មិនហើយរបស់ខ្លួនឯងដែរ...... នៅបន្តិចទៀតទៅ.... មើលនាងពីរបីដង្ហើមទៀតក៏បាន.....។

គឺដូច្នេះ ហើយ..... ប្រឆាំងខ្លួនឯង ថាដើរចេញពីបង្អួចនេះ តែក៏ទៅមិនបាន....ដដែល... រៀងរាល់យប់រក្សាការសម្លឹងទៅរកនាង.... ហើយពីមួយយប់ទៅមួយយប់ កាន់តែនឹកនាងយ៉ាងខ្លាំង ក្នុងពេលភាពមិនសុខស្រួលមួយកំពុងកើតមានឡើងក្នុងអារម្មណ៍។

«ខ្ញុំពន្យារពេលនៅសៀមរាបនេះថែមបីបួនថ្ងៃទៀត! ជួយរៀបចំអ្វីៗនៅទីនោះឱ្យខ្ញុំផង!»

ខ្ញុំសរសេរបញ្ជូនទៅឱ្យអ្នកនៅភ្នំពេញក្នុងដង្ហើមមួយញាប់ប្រញាប់ តែខ្ញុំដើរមកលបមើលនាងក្នុងចលនាដង្ហើមៗយឺតៗ ព្រោះថា.... ក្មេងស្រីស្រស់ស្រទន់អើយ ខ្ញុំមានពេលវេលាជានិច្ចសម្រាប់នាង។

ដូចជានៅយប់នេះទៀត ខ្ញុំចាប់ផ្ដើមរៀបចំរូបទាំងអស់របស់នាងទៅក្នុងកុំព្យូទ័រ ហើយម្រាមដៃខ្ញុំលូកទៅអង្អែលលើសក់រលោងវែងរបស់នាង។

ខ្ញុំថតពីលើបង្អួចទៅ តើធ្វើម៉េចអាចបានបបូរមាត់ និងថ្ពាល់របស់នាងផ្ចិតមកក្នុងសន្លឹកនេះបានទៅ? អុះអូ.... ខ្ញុំឃើញដើមទ្រូង និងគល់សុដន់របស់នាង....

ខ្ញុំចាប់ផ្ដើមនឹកឃើញដល់ស្រីស្អាតសិចស៊ីជាច្រើនដែលបានបណ្ដោយឱ្យខ្ញុំលូកដៃទៅបោចចោលសម្លៀកបំពាក់របស់ពួកគេ។

គិតម៉េចទៅ? ខ្ញុំប្រហែលជាមានមនុស្សស្រីច្រើនពេកទេដឹង នៅក្នុងស្លាកស្នាមយុវវ័យកន្លងមកនេះ ប៉ុន្តែជឿទៅ! បេះដូងខ្ញុំនៅតែទទេស្អាត.... បើទោះណាជាខ្ញុំធ្លាប់ចង់សាកល្បងទទួលភ្ញៀវមួយឬពីរនាក់ចូលមក នៅសាកល្បងដែរសុទ្ធតែបរាជ័យ ប្រហែលជាបេះដូងខ្ញុំគ្រាន់តែជាសណ្ឋាគារផ្កាយ៥មួយដែលមើលទៅឡូយ សង្ហា មើលទៅរមនាសម្រាប់ពួកគេ តែនៅព្រឹកឡើង មិនថាព្រឹកនេះឬព្រឹកបន្ទាប់ ព្រឹកណាមួយ គង់តែគេចាកចេញត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។

សណ្ឋាគារល្អយ៉ាងណា ស្អាតយ៉ាងណា វានៅតែពុំមែនជាផ្ទះ...

សណ្ឋាគារខ្ញុំនេះម៉េចក៏កើតចិត្តសង្ឃឹម ថាបើដាក់ភ្ញៀវតូចម្នាក់នៅខាងក្រោមនោះចូលទៅវាអាច

ក្លាយទៅជា ផ្ទះមួយវិញបាន?

តើអាចដែរទេ?

ខ្ញុំសុំហៅគេ…អូ…អត់ទេ…បងសុំហៅអូនថា «ស្រទន់» តើបានដែរទេ?

………………………………

**វគ្គ**

**អ្នកបរិច្ចាគដ៏ស្រស់សង្ហា**

…..នេះជាព្រលប់ដ៏ ងងឹតចម្លែក ហើយតំណក់ភ្លៀងធ្លាក់ធ្ងន់ៗមកលើផែនដីស្មើនឹងមានព្យុះលាយលំមក ជាមួយ។ ម្តងម្កាលផ្លេកបន្ទោរបានត្រដរប្រយុទ្ធនឹងសន្ទុះខ្យល់ ហើយបង្ហាញពីក្រៅបង្អួចនូវយុវជនមួយក្រុមជ្រកក្រោមសំយាបអគាររដ្ឋ មួយស្រពោនស្ងាត់ ព្រោះភ្លៀងបានបង្អាក់សកម្មដ៏សំខាន់របស់ពួកគេ។

«បានលុយតែប៉ុណ្ណឹងទេ?!»

នាងនិយាយដោយកែវភ្នែកខ្វល់ស្រពោន។ គ្រប់គ្នាក៏សម្លឹងមករកលុយប៉ុន្មានសន្លឹកក្នុងដៃនាង ដែលវាស្មើទៅនឹងក្តីសុបិនរបស់ពួកគេក្នុងការមើលឃើញពន្លឺ ព្រះអាទិត្យចាំងចាចមកវិញសាជាថ្មីគ្រប់មកលើស្រទាប់ភ្លៀងដូច្នេះ ដែរ។

នៅពេលដែលនាងចោលខ្សែភ្នែកទៅរកយុវជនម្នាក់ដែលនៅខាង ស្តាំគេនោះ គេបានគេចចេញពីពន្លឺភ្នែកនាង ព្រោះគេមិនចង់ឱ្យនាងឃើញថា គេក៏ស្រពោនដែរទេ។ នារីវភ្នែកសម្លឹងទៅប្រាង្គប្រាសាទបុរាណដែលបានពួនកប់ក្នុងភាព ងងឹតស្រពិចស្រពិលនៃតំណក់ភិរុណ ដូចគ្នានឹងភ្ញៀវទេសចរស្រីប្រុស តែនាងនៅតែមិនព្រមឈប់ នាងដើរទៅចំពីមុខគេ រហូតដល់គេងើបមុខឡើងហើយបានឃើញស្នាមញញឹមពេញដោយរស្មីក្នុងភ្នែក នាងដែលមុននេះស្រងូត។

«ញញឹមមកភីរៈ!»

នាងនិយាយ ហើយនាំមុខគេដោយសេចក្តីសង្ឃឹមថ្មីលើផ្ទៃមុខ យុវជនក្មេងញញឹមមកវិញបន្ទាន់ ប៉ុន្តែចិញ្ចើមគេនៅតែជះចម្ងល់។

«មេឃរាំងហើយឃើញអត់?!»

នាងនិយាយសាជាថ្មី ហើយចង្អុលទៅកាន់ផ្លូវថ្នល់ គ្រប់គ្នាចាប់ផ្តើមញញឹម ចំណែកភីរៈយុវជនក្មេងលាន់មាត់បន្ទាប់ពីនាង៖

«បើកថ្ងៃហើយ!»

ព្រះអាទិត្យចោលរស្មីសាជាថ្មី ប្រៀបបីដូចជាការងើបមកវិញម្តងទៀត ដើម្បីលំអតំបន់ទេសចរណ៍លំដាប់លេខមួយរបស់ខ្មែរ។ ការផ្លាស់ប្តូររបស់ធម្មជាតិនានាពេលនេះបានទាក់ទាញមនុស្សម្នាចេញដើរចច្រប់ពាសពេញផ្លូវសាជាថ្មី ហាក់ដូចជាមុននេះគ្មានអ្វីកើតឡើងទាំងអស់។

«ភ្ញៀវប្រហែលសប្បាយចិត្តនឹងពន្លឺថ្ងៃស្អាត មេឃស្រលះ តែគ្មានអ្នកណាងាកមកចាប់អារម្មណ៍ការរ៉ៃអង្គាសរបស់ក្រុមយើងទៀតទេ បងវី!»

នាងប្រហែលឈ្មោះ ដាវី ធាវី ទេវី ឬមួយមាណវី បានជាមិត្តរួមក្រុមហៅនាងដូច្នេះ?

តែសម្រាប់ពេលនេះ ឈ្មោះនាងផ្តើមដោយអក្សរអ្វីមិនសំខាន់ទេ សំខាន់ត្រង់ថាប្រាក់ដែលពួកនាងរកបាននៅឆ្ងាយពីតម្រូវការជាក់ ស្តែងចំពោះមុខនៅឡើយ។

នារីមិនឆ្លើយតបនឹងមិត្តរួមក្រុម តែនាងក្រឡេកមករកហ្គីតាចាស់ពណ៌ត្នោតមួយដែលផ្អែកចោលលើផ្ទាក់កៅអី។

មិនដល់មួយដង្ហើមផង ដៃនាងលូកដល់ឧបករណ៍ភ្លេងនោះ ហើយទាញវាមកឱបត្រឹមចង្កេះ។

«ស៊ីវីធ្វើអីហ្នឹង?!»

តាមពិតនាងឈ្មោះស៊ីវីសោះ?...... ភីរៈដឹងហើយថា នាងប្រុងធ្វើអ្វី ប៉ុន្តែគេនៅតែសួរដោយសារមិនជឿការមើលឃើញរបស់ខ្លួន។

ជំនួសវាចាតប នាងញាក់ចិញ្ចើមមួយសំដៅម្ចាស់សំណួរ ហើយម្រាមដៃស្តាំចាប់ផ្តើមទាញឆូតបង្កើរសូរសំឡេងញាប់រន្ថើនមួយ.....

វាជាចង្វាក់បូលឡេរ៉ូដែលហាក់ដូចជាបុរាណសម្រាប់ឆ្នាំ២០១៥ ប៉ុន្តែនៅពីរោះរណ្តំ.....។ ពេលពួកមិត្តភ័ក្តិចំហមាត់ នាងបានឈានចេញទៅមុខថែមពីរជំហានទៀត ធ្វើឱ្យរាងកាយតូចស្តើង និងសំពត់ផ្ការបស់នាងហិចហើរតាមកម្លាំងខ្យល់កំដរចង្វាក់ភ្លេង។

ភីរៈបើកភ្នែកធំៗ ព្រោះតែរំភើប និងភ្ញាក់ផ្អើល គេស្ទុះមករកនាង ហើយសម្លឹងផ្តោតលើស្នាមញញឹមបំព្រងលើបបូរមាត់នាង។

ស៊ីវីអើយ.... នាងពិតជានិមិត្តរូបនៃសុទិដ្ឋិនិយម ក៏ជាដួងព្រលឹងនៃភាពសុខសាន្ត ព្រោះតែអត្តចរិតដែលតែងនាំមកនូវអនុភាពនៃភាសាលួងលោមដាស់តឿនចិត្ត ជានិច្ចកាលទោះក្នុងកាលៈទេសៈលំបាកបែបណា។

ភីរៈគិតទាំងភ្លឹកភ្លាំង ពេលបបូរមាត់នាងចាប់ផ្ដើមហាពាក់កណ្ដាល ហើយអណ្ដាតនាងចាប់ផ្ដើមគ្រលាស់ទៅតាមចង្វាក់ភ្លេង.....

«សូមអូនយល់ចិត្តរៀមផង.... រាល់ថ្ងៃរៀមផ្សងជួបតែស្រី.... ជាតិនេះខ្វះអូនបងនឹងក្ស័យ......»

បទចម្រៀងអធិរាជសំឡេងមាស ស៊ិន ស៊ីសាមុត បែរជាបង្ហើរចេញពីមាត់ភេទផ្ទុយម្នាក់ ប៉ុន្តែហេតុអ្វីមរតកនេះនៅតែមានអនុភាពដូចថ្នាំសណ្ដំបាចសាចព្រោង ព្រាតចេញទៅ?

រហូតដល់ស្នូរកាមេរ៉ាទូរសព្ទលាន់មកឆ្វាច់ៗ ទើបភីរៈងើបមុខពិនិត្យជុំវិញខ្លួន ហើយដឹងថាមនុស្សជាច្រើនបានបោះបង់ចោលការដើរឆ្ពោះទៅប្រាង្គ ប្រាសាទ បញ្ឈប់ដំណើរនៅទីនេះស្ដាប់ចម្រៀង មើលនាងលេងហ្គីតា។ ចុងក្រោយ ពួកគេឱនបរិច្ចាគប្រាក់ទៅក្នុងថ្ពិលដែលមានសរសេរក្រដាសបិទជាប់នោះថា មណ្ឌលកុមារកំព្រា "ស្រែគោក" ។

....វាពិតជាបានផលមែន..... ភីរៈចាប់ផ្ដើមឈានទៅឈរក្បែរនាង ហើយជួយទះដៃបន្ទរ....

ទោះបីថាម្នាក់ៗសុទ្ធតែអាចច្រៀងចម្រៀងនេះបាន ប៉ុន្តែគ្មាននរណាហ៊ានលូកមាត់ជួយច្រៀងនាងទេ ព្រោះខ្លាចថាសំឡេងពួកគេនឹងបំផ្លាញអនុភាពដ៏ទាក់ទាញនៃសូរសំនៀង ក្រអួនពីរោះរបស់នាង។

...ភីរៈបិទភ្នែករេងខ្លួនទទួលយកសុភមង្គលស្រស់បរិសុទ្ធនេះ រហូតដល់ពេលមួយដែលគេចាប់អារម្មណ៍ថាដៃនាងហាក់កេះហ្គីតារង្វើល ជាងមុន ហើយសំឡេងនាងក៏ហាក់រសាយចេញពីអារម្មណ៍ផ្ដោតលើការបញ្ចេញសូរសៀង ទើបគេបើកភ្នែកពិនិត្យមើល។

គេឃើញកង់ម៉ូតូដ៏ធំមួយនៅពីមុខថ្ពិល.... មិនដឹងអ្នកជិះជាអ្នកណាទេ ប៉ុន្តែនៅក្នុងថ្ពិលមានលុយក្រដាសដុល្លារអាមេរិកពីរបីសន្លឹក.... ពុទ្ធោអើយ.... អ៊ីចឹងហើយបានជានាងមិនអាចបន្តច្រៀងតទៅទៀតបាន? គឺនាងមិនអាចធ្វើពើនឹងអ្នកបរិច្ចាគដ៏សែនសប្បុរសនេះ។

«ច្រៀងបានល្អ!»

ម្ចាស់ម៉ូតូនិយាយបីម៉ាត់នេះ ជាមួយសំឡេងពីរោះស្លូតបូតរបស់គេ ធ្វើឱ្យភីរៈងើបមុខរកមើល តែគេមួលហ្គែរចាប់ផ្ដើមចាកចេញទៅ។

គេមិននៅទទួលសូម្បីតែពាក្យអរគុណ ឬសូម្បីតែប្រាប់ថាខ្លួនជានរណា ហើយសូម្បីតែងាកមកឱ្យអ្នកទទួលអំណោយបានស្គាល់មុខ?

ចម្រៀងបញ្ចប់កណ្ដាលទី។ ហ្គីតាក៏បញ្ចប់តាមក្រោយ.... ដោយពួកគេងាកមើលមុខគ្នា។

«អ្ហ៎បង! បងបរិច្ចាគច្រើនណាស់ ប្រាប់ឈ្មោះសិនណ៎ា!»

នាងនិយាយជំនួសឱ្យបទចម្រៀងដ៏ស្រទន់មុននេះ។ ម្ចាស់ម៉ូតូងាកមុខវិញ ប៉ុន្តែវ៉ែនតាការពារពន្លឺថ្ងៃរបស់គេបានបិទបាំងផ្ទៃមុខគេ៥០%ទៅ ហើយ។ ....

នាងឃើញតែមួយប៉ុណ្ណោះ គឺស្នាមខួចតូចមួយក្បែរបបូរមាត់គេ។

«ឯងបានឃើញមុខគេទេ ស៊ីរី!? ស្តាយណាស់ខ្ញុំមើលមិនទាន់!»

ម៉ូតូចាកចេញលឿនណាស់ លឿនរហូតដល់តែនាងមិនអស់ចិត្ត ហើយនៅទ្រឹងតាមសម្លឹងផ្សែងម៉ូតូ។

«សួរថាឯងធ្លាប់ស្គាល់គេទេ ស៊ីរី?!»

ភីរៈពិតជាមិនអាចទប់ការងឿងឆ្ងល់បានមែន បានជាគេបន្តសួរមិនឈប់។

ដូច្នេះនាងតូចក៏តបវិញបែបលេងសើច....

«សង្ហាដូច ហ្វូត យុត្តនា បេះបិទ!»

ភីរៈងៀងភ្នែកមើលនាង នាងឈរនិយាយដោយធ្វើភ្នែកមមី មិនមែនចុះចាញ់សន្ទឹកខ្យល់ទេ តែនាងកំពុងលង់ទៅនឹងការគិតប្រៀបធៀបពិតៗ។

ហួសចិត្ត គេនិយាយខឹងៗភ្លាមៗ

«នៅមកវង្វេងនឹងប្រលោមលោកបានទៀតពេលនេះហើយ?»

ទោះបីយ៉ាងណា នាងបានទទួលហើយនូវអ្វីដែលមិត្តនាងម្នាក់នេះកំពុងត្រូវការ។ រាត្រីនេះជាពេលដែលភីរៈត្រូវចាកចេញ ដូច្នេះហើយទោះបីភ្លៀងផ្គរប៉ុណ្ណា ពួកគេសង្ឃឹមថា សេចក្តីសង្ឃឹមរបស់មិត្តគេម្នាក់នេះក្នុងការបានក្លាយទៅជានិស្សិត នៅមហាវិទ្យាល័យមួយនៅភ្នំពេញនឹងក្លាយជាការពិត។

«ម៉ាក់! នេះជាលុយរកបានសម្រាប់ភីរៈទិញកុំព្យូទ័រទៅរៀនភ្នំពេញ!»

ក្មេងកំព្រាគ្រប់គ្នានៅទីនេះ តែងហៅប្រធានមណ្ឌលថាម្ដាយ ព្រោះពួកគេគ្មានឪពុកម្ដាយទេ។ ស៊ីរី និងភីរៈក៏ដូចក្មេងកំព្រាដទៃដែលធំធាត់ឡើងនៅទីនេះ ហើយពេញវ័យកាលណាតែងជួយរកលុយកាក់សម្រាប់ក្មេងកំព្រាជំនាន់ ក្រោយៗ។

លោកស្រីប្រធានមណ្ឌលលូកដៃមកឱបនាងផ្ទប់នឹងដើមទ្រូង មុនពេលចង្អុលនាងឱ្យសម្លឹងទៅបរិវេណសួនខាងក្រៅ។

នាងងើបមុខបែរទៅរកទីនោះ។

ភីរៈអង្គុយបែរខ្នងលើគែមថ្មក្បែរគុម្ពផ្កាដែលកុមារកំព្រាទាំងឡាយនៅទីនេះតុបតែងដាំជាជួរៗ។

ទោះមិនបានឃើញមុខគេ តែនាងដឹងថាគេកំពុងនឹកកម្សត់អាណិតខ្លួន។

នៅក្រោមពន្លឺចន្ទស្រទន់ខៀវ នាងឈានចេញពីមណ្ឌលទៅអង្គុយក្បែរមិត្តកម្សត់។

«នេះជាលើកដំបូងដែលយើងមានអារម្មណ៍ថា ពិបាកចិត្តហើយនឹកមណ្ឌល!»

ភីរៈនិយាយមួយៗ តែគេមិនបានងាកមកទេ។

ឯស៊ីរីរីតតែឆ្លើយខ្លីតបវិញ៖

«ដូចគ្នា!»

ភីរៈបន្តភ្លាម៖

«ពិបាកចិត្តទីពីរ តើអ្វីខ្លះទៅដែលយើងត្រូវជួបនៅភ្នំពេញ? ហើយតើយើងនឹងមានមិត្តល្អដូចឯងដែរ?!»

ស៊ីរី រេភ្នែកមករកមិត្តដ៏ក្រៀមក្រំនេះ ហើយនាងងើយចោលដីសួនផ្កាដែលទទឹកប៉ប៉ាច់នៃមណ្ឌលក្មេងកំព្រា ហើយផ្តោតលើរបងនិងសណ្ឋាគារខ្ពស់សន្លឹមល្អប្រណីត។

«យើងមិនដល់ថ្នាក់ថាទីនេះជាឋាននរក ហើយខាងណោះជាស្ថានសួគ៌ទេ ភីរៈ តែមើលចុះ ពួកគេញ៉ាំបាយល្ងាចក្រោមសូរសំឡេងវីយោឡុង ឯក្មេងៗនៅទីនេះញ៉ាំបានល្ងាចជួនគ្មានទាំងម្ហូប!»

ភីរៈងើបមុខសម្លឹងសណ្ឋាគារល្អប្រណីតដែលនៅឈរត្រដោមត្រដែតក្រោមរស្មីចន្ទ្រាដ៏តម្អួញកម្សត់។

«ដូច្នេះហើយ ខ្ញុំត្រូវតែរកការធ្វើ ហើយផ្ញើប្រាក់មកជួយថ្លៃម្ហូបពួកគេ ឱ្យក្មេងៗបានទៅរៀនទាំងពោះឆ្អែត!»

ភីរៈនិយាយដោយសម្លឹងមុខមិត្តយល់ចិត្ត ឯនាងក៏ញញឹមតបវិញជាមួយរស្មីនៃពន្លឺភ្នែកបរិសុទ្ធ៖

«មិនមែនមានតែឯងទេ! ខ្ញុំដែរហ្នឹង!»

ភីរៈខំញញឹម ទោះបីភាពក្រៀមក្រំមានទំហំធំជាង តែគេនៅតែប្រឹង ព្រោះអាណិតនាងដែលញញឹមមកមិនឈប់។ នាងនិយាយបន្ត៖

«ខែក្រោយ ខ្ញុំឡើងទៅភ្នំពេញដែរហើយ! យើងនឹងជួបគ្នា!»

នរៈកំព្រាដកដង្ហើមយូរ ហើយងាកមកនិយាយសាជាថ្មីដោយគោះប្រអប់ដៃនាងតិចៗផង៖

«គិតឡើងវិញ ស៊ីរី! ជួនកាលខ្ញុំយល់ថា ឯងមិនបាច់ទៅភ្នំពេញក៏បាន! គ្រួសារនោះជារឿងហួសទៅហើយ ឯងមិនបាច់ទទួលខុសត្រូវទេ! ស្រីពេជ្រស្លាប់យូរហើយ ប្រាប់ការពិតដល់ពួកគេទៅ!»

ធ្លាប់តែសុទិដ្ឋិយ៉ាងណា នាងស្រាប់តែស្រពោនវិញមួយរំពេច។

នាង មិនទាន់ដកភ្នែកចេញពីភីរៈទេ នាងសម្លឹងគេ ឯគេក៏មិចភ្នែកមកទៀតបង្ហាញថា គេពុំមែនលេងសើចឡើយ។ គេហើបមាត់ពន្យល់ភ្លាម ពេលដែលនាងនៅគាំងក្នុងទុក្ខព្រួយ៖

«ស៊ីរី! ការដែលឯងចង់ទៅដើរតួជាបងស្រីគេ ជាប្អូនស្រីគេ ទាំងដែលឯងពុំមែន ទាំងដែលឯងជាអ្នកផ្សេង ជាអ្នកក្រៅសុទ្ធសាធនេះ យើងមិនគាំទ្រទេ! បើឯងស្រណោះពួកម៉ាក ជួយលុយជួយកាក់តាមសមត្ថភាពទៅ! ប្រាប់ពួកគេត្រង់ទៅថា បងគេ ស្រីពេជ្រស្លាប់ហើយ!»

បបូរមាត់នាងកម្រើក ចង់និយាយតវ៉ា តែរកហាមិនបាន។ ភីរៈដឹងថា បេះដូងនាងកំពុងខ្ទេចខ្ទាំ ហើយនាងកំពុងនឹករលឹកទៅដល់មិត្តកំព្រាដ៏កម្សត់ម្នាក់នោះ...... ស្រីពេជ្រ។

«ប្អូនយើងជាប្អូនរបស់ឯងណាស៊ីរី! បងស្រីយើងជាបងរបស់ឯង! ពួកគេទន់ខ្សោយណាស់ ឯងសន្យាណ៎ាថាឯងមើលពួកគេជំនួសគ្នា!»

បណ្តាំរបស់ស្រីពេជ្រមុនពេលស្លាប់នៅឯមន្ទីរពេទ្យ លាន់មករងំក្នុងបេះដូងនារីកំព្រា។

កែវភ្នែកនាងដែលរេសម្លឹងភីរៈប្រាប់ស្រេចបាច់ហើយនូវចម្លើយថា «ធ្វើមិនបាន! លេបសន្យាមិនកើត!»។

ភីរៈក្តាប់មាត់ងាកមុខចេញ គេរអ៊ូ៖

«ធ្វើឡប់ៗ!!! ៧ឆ្នាំហើយ សរសេរសំបុត្រចុះឡើង ផ្ញើលុយទៅគេរហូត ហើយប្រាប់ថាខ្លួនឯងជាស្រីពេជ្រ! ឯងកុហកគេបានការអី? បងគេស្លាប់ហើយ ប្រាប់ទៅគេអាចនឹងឈឺចាប់ឥឡូវ តែវាមានអីមិនល្អ? កុហកអស់នេះអ្ហេះដែលល្អ? កោតដល់ហើយ! ទៅៗ ប្រាប់គេតាមត្រង់ទៅ ហើយជួយលុយកាក់គេខ្លះៗទៅវាបានទៅហើយ!»

នាងតបមកវិញតិចៗ៖

«ខុសគ្នា ភីរៈ! សេចក្តីសង្ឃឹមដែលថាមានញាតិម្នាក់នៅរស់ វាខុសពីសេចក្តីអំណរដែលគ្រាន់តែទទួលបានលុយកាក់ផ្ញើទៅ ឯងយល់ទេ?!»

សំឡេងនាងលាន់មកវិញពីក្រោយខ្នងគេដែលងាកមុខចេញ ដើម្បីបន្តសម្លឹងនាងកុំឱ្យលង់ចិត្តអាណិតភាពស្មោះត្រង់ក្នុង កែវភ្នែកនាង។

«យើងមិនយល់ទេ! យើងមិនខ្វល់! ដែលឯងត្រូវទៅភ្នំពេញ ហើយទៅរស់នៅជាមួយគ្រួសារអ្នកដទៃ ហៅគេថាបងហៅគេថាប្អូន ហើយរកស៊ីចិញ្ចឹមពួកគេ?!»

«ក៏មានអីមិនល្អ!? យើងក្បាលមួយលើលោកនេះមែនអត់? មានអ្នកមកហៅថាបង មកហៅថាប្អូនក៏

ល្អជាងគ្មានដែរមែនដែរទេ? ហើយមិត្តយើងបានប្រាប់យើងថា ប្អូនគេជាប្អូនរបស់យើង! គេមុនដាច់ខ្យល់ក៏ផ្ដាំយើង ឯងឱ្យយើងបិទភ្នែកបំភ្លេចវាបានដែរភីរៈ?!»

«តែចំណងគ្រួសារបងប្អូនកុំស្មានថាលេងធេង! វាមិនមែនល្ខោនភាគទូរទស្សន៍ដែលងាយៗស្រួលទេ!»

នាងងើបមុខសម្លឹងគេដែលជាមិត្តដ៏ល្អបំផុត និងជាអ្នកដែលតែងគាំទ្រនាងបំផុត ពេលនេះបានជំទាស់នាងក្នុងការចេញទៅបំពេញកាតព្វកិច្ច បំពេញសន្យា។

សូរទារកយំលាន់មកពីចម្ងាយ.... នាងបែរមុខសម្លឹងទៅមណ្ឌល។ នៅទីនោះក្មេងជំទង់ម្នាក់កំពុងបីលួងទារកតូចក្នុងដៃតែយំមិនឈប់ សោះ។ ស៊ីរីងាកមករកភីរៈដោយនិយាយ មុនពេលក្រោកចេញ៖

«យើងមិនបោះបង់ពាក្យសន្យានេះទេ! ឯងក៏ដឹងដែរ! កុំមកនិយាយរឿងនេះទៀត! ចាំជួបគ្នានៅភ្នំពេញទៅដេកទៅ! ស្អែកត្រូវឡើងឡានពីងងឹតផង!»

នាងចាកចេញទៅរ៉ុយដើម្បីទទួលយកទារកកំព្រាមកបីត្រកង ក្រោមក្រសែភ្នែកស្រពោនតាមសម្លឹងរបស់ភីរៈ។

ស៊ីរីតែងទុកក្មេងៗកំព្រាទាំងឡាយនៅទីនេះដូចប្អូន រាប់ចាប់តាំងពីទារករហូតដល់ក្មេងជំទង់។ នាងគិត សូម្បីតែមិត្តដែលស្លាប់បាត់ទៅហើយផង។

ភីរៈមើលឃើញពីស្រមោលនរណាម្នាក់ដែលពេញដោយមេត្តាធម៌គុណធម៌ សប្បុរសធម៌ នៅក្នុងរាងកាយនារីវ័យក្មេងម្នាក់នេះ ហើយវត្ថុទាំងបីគឺជាចំណង់ចំណូលចិត្តដ៏សាមញ្ញដែលនាងប្រព្រឹត្ត ដោយធម្មជាតិ។ ដូច្នេះហើយ នាងតែងតែអាចញញឹមបាននឹងជីវិតដ៏បរិសុទ្ធរបស់នាង។

បទចម្រៀងរាជិនីសំឡេង រស់ សេរីសុធា លាន់មកស្រទោរស្រទន់តាមខ្យល់..... «រាត្រីនេះព្រះចន្ទ្រាភ្លឺថ្លា.....ចិន្ដាសែនខ្វល់ម៉្លេះទេ.... ស្រមៃគ្រាមួយនៅក្រោមដួងខែ.....»

គឺនាងច្រៀងទៀតហើយ.... នាងច្រៀងបំពេទារកនោះ បានជាសំឡេងស្រែកយំបានរលត់បាត់.....ទារកគ្មានម្ដាយប្រាកដជាសុខសាន្តក្រោមដៃនាង.... ភីរៈដឹងហើយ គេក្រោកចេញលែងសម្លឹងនាងទៀត។

យុវជនក្រោកចោលសួនផ្កានារាត្រីចុងក្រោយក្នុងនាមក្មេងមណ្ឌល តែបេះដូងគេនៅតែតវ៉ាស្ងាត់ៗ៖

«ស៊ីរី! យើងឃាត់ឯង ប្រហែលជាមកពីយើងខ្លាចឯងទៅភ្នំពេញត្រូវគេធ្វើបាប! ក៏ប្រហែលយើងខ្លាចទីនេះលែងមានពន្លឺព្រះខែដ៏ស្រទោរស្រទន់ និងស្នាមសើច បទចម្រៀងលួងលោមរបស់ឯង! តែបេះ

យើង គ្មានស្រីណាជំនួសឯងបានទេ!»

នាងដឹងថាគេក្រោកចេញទៅហើយ។ គេប្រហែលមិនចង់ឮសំឡេងច្រៀងនេះ ឬគេមិនចង់ស្រណោះស្រណោកសោកស្ដាយយូរ។

ស្រីតូចឱនមកថើបទារក ហើយបន្លប់ទុក្ខព្រួយដោយច្រៀងបន្ត....

«វាំយោបក់មកនាំយកក្លិនផ្កា.... ស្នេហារុះរោយស្រពោន.... ធ្វើម្ដេចសាងស្នេហ៍សាងទូកសាងក្បូន... បើរូបអូន.....»

សំឡេងទ្រលាន់មកអមយ៉ាងលន្លោច ធ្វើឱ្យអ្នកច្រៀងកាន់តែចូលអារម្មណ៍ច្រៀង ទម្រាំពេលដែលនាងដឹងខ្លួន នាងបន្ថយសូរដោយងើយមុខឡើងទៅរកប្រភពនៃឧបករណ៍ភ្លេងបុរាណ.....

បុរសម្នាក់ឈរនៅគែមបង្កាន់ដៃនៃជាន់ទីមួយសណ្ឋាគារកូតទ្រលម្ហូញ លន្លោចនេះដោយបិទ ភ្នែកទាំងគូរបស់គេមិនរវល់នឹងពន្លឺភ្នែកនាងឡើយ។

...ហួសហេតុពេកហើយ គេមានសិទ្ធិអីមកកូតបទដែលយើងកំពុងច្រៀង...?

នាងគិត ហើយក៏ក្រមួចមាត់សម្លក់គេ ដោយបញ្ឈប់ការច្រៀងបទចម្រៀងទាំងស្រុង ធ្វើឱ្យគេបើកភ្នែកមកវិញ ហើយឱនរកមើលនាង។

នាងបោះបង់ចោលការសម្លឹងគេដោយបែរចូលទៅក្នុងមណ្ឌល.....

ប៉ុន្តែម្ចាស់ទ្រប្រហែលជាស្មានខុសហើយ.... ដែលគិតថា នាងនឹងអភ័យទោសឱ្យគេបោះបង់ចោលការសួរនាំដេញដោល។

តាមពិតគឺ នាងយកក្មេងតូចទៅដាក់គេងក្នុងមុង រួចស្រូតរត់ឡើងទៅជាន់ខាងលើចេញមកខាងក្រៅប្រឈមនឹងអ្នកប្រគំ ភ្លេងឱ្យបានឈរកម្ពស់ទល់គ្នា។

គេខ្ពស់ស្រាវ ហើយរាងស្ដើង ប៉ុន្តែដំណើរដែលដើរមួយៗមកធ្វើឱ្យនាងក្រពាត់ដៃមើលមុខនោះ គឺគេដើរមាំៗ បង្ហាញពីសុខភាពរឹងប៉ឹង និងកាយសម្បទាស័ក្តិសមល្អ។

នាងក្រពាត់ដៃសម្លឹងគេ ទាំងដែលគេញញឹម ហើយមើលត្រឡប់មកកាន់នាងទាំងមិនមាត់មិនកដូចគ្នា.....

អគារខាងក្មេងកំព្រាគ្មានភ្លើងបំភ្លឺគ្រប់ទេ បានជាគេមើលមិនឃើញទឹកមុខនាង ប៉ុន្តែនៅខាងគេឯណោះវិញពេញដោយអំពូលទំនើបជះចេញមកនូវពន្លឺពណ៌ មាសច្រាល បង្ហាញពីទិដ្ឋភាពរស់នៅសោយសុខ អមកំដរទឹកមុខប្រិមប្រិយនៃម្ចាស់បន្ទប់ផង។

«អ្នកណាឱ្យបងឯងកូតទ្រ?!»

នាងចាប់ផ្ដើមសួរដោយខំធ្វើមុខស្មើដូចជាខឹង ប៉ុន្តែតាមពិតនាងមិនបានខឹងទេ គ្រាន់តែនាងរពឹសមាត់ចង់រករឿងមនុស្សចម្លែកនេះ។

គេញញឹមសម្លឹងនាង ពេលដែលនាងដើរឆ្ពោះមកកាន់តែជិត ហាក់ដូចជាក្លាហានណាស់។

សំឡេងគេតបមកមួយៗឆ្លងកាត់ចន្លោះឃ្លាតគ្នារវាងសំណង់ទាំងពីរមកប៉ះដល់ត្រចៀកស្រីតូចទងវង៖

«ស្រុកនេះគេហាមមិនឱ្យកូតទ្រ?»

«ធ្វើខុសហើយ មកឌឺគេទៀត?!»

«និយាយប៉ុណ្ណឹងទុកថាឌឺ? កូតទ្រប៉ុណ្ណឹងទុកថាខុស?»

«សម្ដីបានណាស់!!! ខ្ញុំអ្នកសួរ មិនមែនបងឯងអ្នកសួរទេ!»

គេអស់សំណើចដែលនាងសុខៗធ្វើដូចខឹងមែន តែគេអាចកាត់យល់បានថានៅសុខៗ នាងកំពុងច្រៀង មានគេមកកូតទ្រកំដរជាមនុស្សមិនដែលស្គាល់ ទំនងជានាងអៀនច្រើនជាងបានជាតាំងចិត្តរត់ឡើងមករករឿងនាំឈ្លោះ។

---------------------------

បុរសញញឹមដាក់ឧបករណ៍ភ្លេងទៅលើកៅអីផ្ដេកប្រកបដោយផាសុកភាពរបស់គេ រួចងាកមកច្រត់ដៃទាំងទ្វេលើបង្កាន់ដៃថ្ម សម្លឹងនារីនៅអគារជិតខាង។

គេនិយាយមួយដោយមិនដកភ្នែកពីនាង៖

«ច្រៀងបានល្អ!»

នាងក្រេបួចមាត់ទប់កុំឱ្យស្នាមញញឹមរីករាយរបូតចេញមកឱ្យគេឃើញបាន ព្រោះបេះដូងនាងលោតនឹងពាក្យសរសើរក៏ដូចជាភាពស្រស់សង្ហានៃគូ សន្ទានេះ។

ស្នាមញញឹមគេក្រេបួចតបមកនាំយកជាមួយស្នាមខួចដែលនាងនៅចាំ ហើយពាក្យបីម៉ាត់អម្បាញ់មិញរបស់គេហាក់បន្ទរត្រឡប់មកវិញផ្ទួន ៗក្នុងអារម្មណ៍នាង។

នាងបើកភ្នែកមូលក្លុំរលោងច្រាល ព្រោះនាងនឹកឃើញថាពាក្យនេះដូចណាស់ គឺអ្នកណាម្នាក់ដែលទើបតែសរសើរនាង.... ហើយនឹងស្នាមខួចរបស់គេ....

«បងឯងទេ?»

គេញញឹមមិនមាត់មិនកអ្វីដោយនៅរង់ចាំមើលនាង។

គេដឹងថា នាងកំពុងចំណាំគេបានថាជាអ្នកណា ហើយរលឹកមកវិញស្រេចថា នាងមិនមែនទើបតែជួប គេនេះជាលើកដំបូងឡើយ។

នាងនឹកដល់បុរសម្នាក់ដែលបានដាក់លុយមួយចំនួនទៅក្នុងថ្ពិលនាង កាលពីល្ងាច ហើយដែល ប្រញាប់ប្រញាល់ហួស បន្សល់ឱ្យនាងត្រឹមតែពាក្យសរសើរបីម៉ាត់ដដែលនេះ។

នាងទម្លាក់ដៃដែលក្រពាត់ ហើយហាក់ត្រេកអរដែលបានជួបគេសាជាថ្មី.....

គេនៅញញឹម ហើយនិយាយបន្ថែមៈ

«ឃើញយើងច្រៀងពីរោះពេក ពីណាទ្រាំមិនកូតភ្លេងបានទៅ?!»

នាងជ្រប់មុខញញឹមដែលខ្លួនឯងនៅមិននៅ មករករឿងប៉ះអ្នកមានគុណ។

ស្រីតូចលូកដៃទៅរកបង្កាន់ដៃ ហើយឱនទៅរាក់ទាក់គេ។

«ហើយបងឯងបរិច្ចាគលុយរបៀបអី? ឈ្មោះក៏មិនទុក?!»

«ប្រញាប់!»

«ប្រាប់ទៅណា?!»

«ពិតជាកំពូលអ្នកសួរមែនយើងនេះ!»

«ខ្ញុំឈ្មោះស៊ីរី!»

តែនាងហាក់ផ្លាស់ប្ដូរលឿនពេក ពីអារម្មណ៍រករឿងមកជារាក់ទាក់ ហើយប្រាប់ឈ្មោះទាំងគេនោះមិន បានសួរ។

«ដឹងតើ!»

«ដឹងអីទៅ?!»

«ដឹងថាឈ្មោះអ៊ីចឹង ប៉ុន្តែអត់ពីរោះបានជាខ្ជិលហៅ!»

«អីគេ? បងឯងជួបគេភ្លាម មករិះគន់ទាំងឈ្មោះគេទៀត!»

«យើងដូរឈ្មោះទៅ! ស្រទន់! ហៅថាស្រទន់ទៅពីរោះជាង!»

នាងអៀននឹង កែវភ្នែកមមីរ៉ូមែនទិករបស់គេដ៏កក់ក្ដៅ និងស្នាមញញឹមរបស់គេ ចុះចាញ់សម្ដីស្រាលៗ សុភាពរាបសាររបស់គេ ហើយបាក់ចិត្តនឹងឈ្មោះដែលគេចង់ហៅនាង។

ថ្ពាល់ទាំងសងខាងរបស់ស្រីតូចក្រហមងាំង មិនដឹងគេបានឃើញច្បាស់ដែរទេ តែនាងពិតជាស្អាត

ស្រទន់ សមនឹងសូរសំនៀងរបស់នាងមែន។

នាងប្រកែកបន្លប់៖

«គ្មានពីណាឈ្មោះអ៊ីចឹងទេ!»

«ព្រោះគេអត់មានសំឡេងពីរោះស្រទន់ដូចយើង!»

«បងឯងបញ្ចោរគេ ពូកែណាស់!»

«អត់ទេស្រទន់! បងនិយាយមែន!»

នាងងើបមុខសម្លឹងគេដោយកែវភ្នែកពេញចិត្ត ហើយភក្ត្រាប្រុសស្រីទាំងពីរបានផ្ដោតរកគ្នា លែងខ្វល់នឹងគម្លាតប្រមាណពីរម៉ែត្រនៃលំហដែលខណ្ឌចែកបង្កាន់ដៃ ទាំងសងខាង។

ស្នេហាមួយនេះ បើកើតឡើងឆាប់យ៉ាងនេះ ប្រាកដជាមិនសមទំនងហើយ ប៉ុន្តែអនុភាពអ្វីម្យ៉ាងបានធ្វើឱ្យវាចេញជារូបរាងពិតមែន រហូតដល់នាងដឹងខ្លួនមកវិញថា ហេតុអ្វីមកចុះចាញ់សម្ដីគេជាមួយពាក្យសរសេរត្រឹមពីរបីម៉ាត់នេះ? សមដែរទេ?

នាងងាកមកចេញវិញ ឈប់មើលផ្ទៃមុខសុភាពបុរស ហើយក្រឡេកប៉ះកែវភេសជ្ជៈ និងចានផ្លែផ្កាដែលរៀបសមពិធីការ ទុកចោលលើតុតូចក្បែរជងទ្រូវរបស់គេ។ នាងរភ្នែកពាសពេញសម្លឹងទៅផ្ទះបន្ទប់ប្រណិតក្រហមឆ្អៅពីក្រោយស្មា ធំបើកសាយរបស់បុរសនេះ ហើយភ្លាត់រអ៊ូ៖

«តាមពិតបងឯងជាអ្នកមាន?!»

និយាយចប់ហើយ នាងនៅតែមិនដកភ្នែកចោលទិដ្ឋភាពស្កុកស្ដម្ភនៅខាងក្នុងបន្ទប់សណ្ឋាគារឡើយ។

មិន ខ្វល់ថាគេគិតយ៉ាងណា តបយ៉ាងណា នាងពិតជាមិនដែលបានឃើញទិដ្ឋភាពបន្ទប់គេងស្រស់ស្អាតបែបនេះពីមុន មកទេ ព្រោះមិនដែលឡើងមកទីនេះ។

«អ្នកមានអីទៅ?!»

គេសួរមកវិញតិចៗ ដកអារម្មណ៍នាងឱ្យផ្ដោតមករកផ្ទៃមុខគេវិញ។

មាត់គេនៅតែញញឹម តែភ្នែកគេដៀងលួចមើលមកបន្ទប់ដេកពីក្រោយខ្នងខ្លួន.... គេយល់ហើយថាហេតុអីនាងគិតដូច្នេះ.....

«បើមែន!»

នាងឌឺដងដាក់គេ ដែលគេមិនទទួលស្គាល់ពីជីវិតរស់នៅដ៏ប្រសើររបស់ខ្លួនឯង។

បុរសញញឹមនិយាយតបមកកាន់កែវភ្នែកនាង៖

«ជាអ្នកសុំទានបានវាត្រូវ!»

«ផ្ដាសណាស់! សុំទានអ្វី? សុំទានគេងកន្លែងឡូយម៉េះ? បើអ៊ីចឹង គេទៅសុំទានអស់ហើយ!»

គេញញឹម សម្លឹងមាត់ប៉ប៉ាច់របស់នាង។

គេសុភាពទាំងស្នាមសើច ទាំងសព្ទសំឡេងដែលនិយាយចេញមកទាំងខ្សែភ្នែកដែលមើលមក នាង តែគេមិនតបអ្វីនឹងនាងទៀតឡើយ។

នាងឃើញគេមិនឆ្លើយ និយាយបន្តវ៉ាវ៖

«អូដឹងហើយ បងឯងកំពុងដៀលថា ខ្ញុំនេះដាក់ផ្ទិលច្រៀងសុំទានគេ!»

នាងជ្រប់មុខដោយខូចចិត្ត តែគេចង្អុលទៅរកទ្រ៖

«អត់ឯណា! បងថា បងនេះហើយសុំទានគេ! មិនឃើញទ្រទេអ្វី!?»

នាង ងើបមុខសម្លឹងឧបករណ៍តន្ត្រី។ នាងក៏ដឹងដែរថា នៅក្នុងប្រទេសនេះ មនុស្សខ្លះនៅតែមានជំនឿអកុសលថា អ្នកចេះលេងទ្រច្រើនតែជាមានរបរសុំទាន ឬលេងចាប៉ីដងវែង មុនក្រោយនឹងខ្វាក់ភ្នែកជាដើម....។

នាងខ្ទប់មាត់សើច ហើយសម្លឹងតបទៅរកគេជាថ្មី ឯគេក៏ញញឹមពេបមាត់ ហើយញាក់ស្មាតបមកកាន់នាងវិញ ធ្វើឱ្យនាងរឹតតែអស់សំណើច សើចជាប់រដឹក។

នាងសើចបង្ហាញធ្មេញពីរជួរសដូចផ្កាម្លិះ ប៉ុន្តែអ្វីដែលរឹតតែស្អាតគឺ ទឹកចិត្តនិងកាយវិការស្មោះបរិសុទ្ធរបស់នាង។

គេ សម្លឹងនាងភ្លឹក.... គេមិនឃើញស៊ីវី ប៉ុន្តែគឺបានឃើញស្រីម្នាក់ដែលពិសេស..... អាចទុកចិត្ត..... អាចត្រជាក់ចិត្ត..... អាចរសាយចិត្ត.... ហើយងាយនិយាយអ្វីៗចែករំលែកគ្នាដោយគ្មានទុក្ខព្រួយកង្វល់។

សំឡេងនាងកាត់ផ្ដាច់អារម្មណ៍ត្រេកត្រអាលរបស់គេ៖

«បងឯងសុំទានអាម៉េចទៅ បានជាបានលុយច្រើនម្ល៉េះមកបរិច្ចាគរាប់រយដុល្លារ ហើយមិនឱ្យប្រកាសឈ្មោះទៀត? ហើយមើលចុះ មើលកន្លែងដែលបងឯងនៅ? អ្នកក្រឯណាទៅដែលមានលុយមកគេងកន្លែងថ្លៃបែបនេះ?»

គេដកអារម្មណ៍មកវិញ ហើយឆ្លើយ៖

«អ្នកបរិច្ចាគប្រាក់ច្រើន ពុំមែនសុទ្ធតែជាអ្នកមានទេ តែប្រហែលមកពីគេយល់ការលំបាករបស់អ្នកសុំ គឺអ្នកដែលកំពុងត្រូវការ!»

នាងរុះរោយស្នាមញញឹម ហើយនឹកដល់ភីរៈ។

ស្រីតូចចងចិញ្ចើមតិចៗសួរទៅបុរសសង្ហានៅចំពោះមុខ៖

«ចុះបងឯងប្រញាប់ម្ល៉ឹងៗ ដឹងយ៉ាងម៉េចថា ពួកខ្ញុំកំពុងត្រូវការ?»

«យើងឡើងដេញហ្គីតា ហើយច្រៀងបទប្រុសទៀត មិនផ្អើលរលំប្រាសាទក៏ផ្អើលសត្វស្លាបហើរចោលទន្លេសាបអស់ដែរ!»

គេញញឹម.... ហើយស្នាមខួចរបស់គេចាក់ទម្លុះបេះដូងស្អាតឆ្វង់របស់នាង។

គេនិយាយ... សំឡេងរបស់គេក៏មានអនុភាពឱ្យនាងចង់ផ្ទៀងស្ដាប់ មិនចង់ឱ្យរំលងទៅសូម្បីមួយម៉ាត់ណា។

«ម៉េចដែរ? ហើយបន្ទប់នេះទៀត! មិនមែនឱ្យតែគេងសណ្ឋាគារល្អ ក៏ចេញលុយខ្លួនឯងនោះទេដឹងនៅ?!»

គេចំអន់នាងលេង តែនាងយល់ថា គេជាមនុស្សឆ្លាត ហើយពូកែនិយាយក៏ពូកែលើកទឹកចិត្តព្រមទាំងមានសន្ដានចិត្តសប្បុរសផង។

នាងញញឹមបញ្ចេញការទាក់ចិត្តរបស់ខ្លួនឱ្យគេដឹងពេញទំហឹង។

ភ្នែកនាងក្រឡេកទៅចំកុំព្យូទ័រគេដែលនៅលើពូកចុងជើង។

«បងឯងធ្វើការអី?!»

«សិល្បករ!»

គេឆ្លើយលឿនហើយខ្លី ឯភ្នែកសម្លឹងនាងជានិច្ច។ ឃើញនាងញញឹម គេសួរវិញ៖

«ម៉េចបានញញឹម? មានសំណួរទៀតអត់កូនក្មេង?!»

«បើជាសិល្បករ មានតែបងឯងអត់ល្បី? ព្រោះខ្ញុំអត់ដែលស្គាល់!»

«អូ ឱ្យតែសិល្បករត្រូវតែមានគេស្គាល់ហ្មែន!?»

«ត្រូវហើយ បើមិនមានគេស្គាល់ ធ្វើសិល្បៈដើម្បីអី?!»

«ចុះចេះកូតទ្រ មិនមានគេស្គាល់ ហៅថាសិល្បករអត់បានទេ?!»

«បើអ៊ីចឹង ខ្ញុំចេះច្រៀងក៏ជាសិល្បករបាត់ទៅហើយ?!»

«ពីណាថាអត់?!»

«ល្អណាស់! ស្អែកនេះ ពេលខ្ញុំទៅច្រៀងសុំលុយ ចាំបងឯងទៅកូតជាមួយគ្នាបានមួយក្រុម!»

«សុំអីទៀតហើយ ក្រែងពួកម៉ាកយើងបានគ្រប់ទិញកុំព្យូទ័រហើយអ្ហី?!»

នាងបើកភ្នែកធំៗសម្លឹងគេទាំងមាត់បន្តស្រដី៖

«អូហូ! ដឹងហើយ បងឯងតាមដានខ្ញុំតាំងពីនៅខាងក្រោម!! ពេលខ្ញុំនិយាយជាមួយភីរៈក៏បងឯងឮទាំងអស់ដែរ!»

គេញញឹមញាក់ស្មាតិចៗតបមកវិញ៖

«អាហ្នឹង គេមិនហៅថាតាមដានទេ!»

«តាមដានចង់ដឹងរឿងអ្នកស្រុកច្បាស់ណាស់ បងឯងប្រុសចរិតស្រី!»

«យើងនិយាយឮៗ និយាយក្នុងធម្មជាតិពេលយប់ស្ងាត់ អ្នកណាមិនឮ បានវាចម្លែក!»

ស្រីតូចបើកភ្នែកធំៗ ខ្ទប់មាត់ ហើយបារម្ភ។ នាងសួរខ្សឹបៗ៖

«បងឯងឮទាំងអស់មែន?!»

ត្រូវហើយ គឺគេស្ដាប់ឮគ្រប់ៗរឿង រួមទាំងរឿងដែលនាងត្រូវទៅភ្នំពេញបន្លំជាបងស្រី ប្អូនស្រីអ្នកណារកការងារធ្វើជួយចិញ្ចឹមអ្នកណា រក្សាសន្យាជាមួយអ្នកណា គឺគេដឹងគ្រប់យ៉ាង។

ដូច្នេះហើយ ពេលនាងអេះអុញនៅស្ងៀម ដៃគេលូចហុចក្រដាសតូចមកមួយ៖

«ទៅភ្នំពេញខលមកបង! បងប្រហែលជួយរកការងារឱ្យធ្វើបាន!»

នាងលូកដៃទទួល តែលំហឃ្លាតគឺឆ្ងាយបន្តិច គេខំបោះដៃមក.... តែនាងទាបដៃក៏ខ្លី.... តើស្រីតូចស្រទន់លូកចាប់គេដល់ដែរទេ?